# របាយការណ៍លទ្ធផលការងារឆ្នាំ ២០២២
# និងលើកទិសដៅការងារឆ្នាំ ២០២៣ របស់មន្ទីរអភិវឌ្ឍន៍ជនបទ ខេត្តព្រះសីហនុ

## សេចក្តីផ្តើម

មន្ទីរអភិវឌ្ឍន៍ជនបទខេត្តព្រះសីហនុ ទទួលបន្ទុកសម្របសម្រួលសកម្មភាព ក្រោមការដឹកនាំដោយផ្ទាល់របស់ **ឯកឧត្តមបណ្ឌិតសភាចារ្យ អ៊ុក រ៉ាប៊ុន** រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ តាមខ្សែបណ្តោយ និង **ឯកឧត្តម គួច ចំរើន** អភិបាលនៃគណៈអភិបាលខេត្តព្រះសីហនុ តាមខ្សែទទឹង ព្រមទាំងសហការណ៍ជាមួយបណ្តាមន្ទីរពាក់ព័ន្ធនានាក្នុងខេត្ត អង្គការក្នុង និងក្រៅរដ្ឋាភិបាល ផ្នែកឯកជន សប្បុរសជម៌ និងសហគមន៍មូលដ្ឋាន ក្រោមការចង្អុលណែនាំដោយផ្ទាល់ពីគណៈអភិបាលខេត្ត ក្នុងគោលដៅរួមចំណែកលើកស្ទួយកម្រិតជីវភាពរស់នៅខាងផ្នែកសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ របស់ ប្រជាពលរដ្ឋនៅក្នុងខេត្ត ជាពិសេសនៅទីជនបទ ដើម្បីចូលរួមកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ ក្នុងការអភិវឌ្ឍតាមគោលដៅជាយុទ្ធសាស្ត្ររបស់រដ្ឋាភិបាល និងក្រសួងអភិវឌ្ឍន៍ជនបទ។

ខេត្តព្រះសីហនុ ស្ថិតនៅប៉ែកនិរតីនៃប្រទេសកម្ពុជា មានចម្ងាយប្រមាណ ២៣០គីឡូម៉ែត្រ ពីរាជធានីភ្នំពេញ ចែកចេញជា០២ក្រុង ០៣ស្រុក មាន០៦សង្កាត់ និង២៣ឃុំ មាន១១១ភូមិ មានឆ្នេរសមុទ្រលាតសន្ធឹងប្រវែង១៧៥.៨១គីឡូម៉ែត្រ មានកោះចំនួន៣០កោះ ថ្មដុះចំនួន០២ និងថ្មប៉ប្រះទឹកចំនួន០៥។ ផ្ទៃដីសរុប ២.៦៥៨,៩០ គីឡូម៉ែត្រការ៉េ ប្រជាជន៥០.៥២២គ្រួសារ ស្មើនឹងចំនួន ២២៩.៣៣២នាក់)ស្រី១១៥.៥២១នាក់(។ ដង់ស៊ីតេប្រជាជន ៨៦.២៤នាក់ ក្នុង០១គីឡូម៉ែត្រការ៉េ អត្រាកំណើនប្រជាពលរដ្ឋប្រចាំឆ្នាំ១.៩៩ភាគរយ។

## I. សមិទ្ធផលសម្រេចបាន

### ១.ការពង្រឹងស្ថាប័ន និងកសាងសមត្ថភាព

### ១.១.ការងាររដ្ឋបាល និងបុគ្គលិក

មន្ទីរអភិវឌ្ឍន៍ជនបទខេត្តព្រះសីហនុ មានមន្ត្រីរាជការសរុបចំនួន២០រូប (ស្ត្រី០១រូប) ដឹកនាំដោយប្រធានមន្ទីរ០១រូប និងអនុប្រធានមន្ទីរ០៣រូបជាជំនួយការ ប្រធានការិយាល័យ ០៧រូប អនុប្រធានការិយាល័យ ០៧រូប (ស្ត្រី០១រូប) និងមន្ត្រី០២រូប ដោយចែកចេញជា១០ការិយាល័យ រួមមាន៖

- ការិយាល័យរដ្ឋបាល និងកិច្ចការទូទៅ
- ការិយាល័យគណនេយ្យ និងហិរញ្ញវត្ថុ
- ការិយាល័យផែនការ និងស្ថិតិ
- ការិយាល័យបណ្តុះបណ្តាល និងស្រាវជ្រាវ
- ការិយាល័យអភិវឌ្ឍន៍ជនជាតិភាគតិច

- ការិយាល័យផ្គត់ផ្គង់ទឹកជនបទ
- ការិយាល័យថែទាំសុខភាពជនបទ
- ការិយាល័យអភិវឌ្ឍន៍សហគមន៍
- ការិយាល័យអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទ
- ការិយាល័យផ្លូវជនបទ

ការិយាល័យបានបំពេញតួនាទីយ៉ាងសកម្ម ក្នុងការសម្របសម្រួល គ្រប់គ្រងសកម្មភាពរបស់មន្ត្រីរាជការ បញ្ជីវត្តមាន ការធ្វើលិខិតយុត្តិកា គ្រប់គ្រងឯកសារ លិខិតស្នាម ការទទួល និងបញ្ជូនលិខិតរដ្ឋបាលនៅក្នុងក្របខណ្ឌខេត្តទៅក្រសួង និងមន្ទីរអង្គភាពនានា ដែលពាក់ព័ន្ធទាន់ពេលវេលា ចាត់ចែងបេសកកម្មជូនមន្ត្រីរាជការ និងមានការទំនាក់ទំនងល្អ។

- បានទទួលលិខិតចូលចំនួន ២៣៧ច្បាប់ ក្នុងនោះលិខិតចូលពីបណ្តានាយកដ្ឋាន និងក្រសួងអភិវឌ្ឍន៍ជនបទ មានចំនួន៦៤ ច្បាប់ និងលិខិតចូលពីបណ្តាក្រសួង រដ្ឋបាលខេត្ត និងមន្ទីរ អង្គភាពនានា មានចំនួន១៧៣ច្បាប់
- បានធ្វើលិខិតចេញចំនួន ៣៧៣ច្បាប់ ក្នុងនោះលិខិតចេញទៅបណ្តានាយកដ្ឋាន និងក្រសួងអភិវឌ្ឍន៍ជនបទ ចំនួន២៥០ច្បាប់ និងលិខិតចេញទៅបណ្តាក្រសួង រដ្ឋបាលខេត្ត និងមន្ទីរ អង្គភាពនានា ចំនួន១២៣ច្បាប់
- បានរៀបចំកិច្ចប្រជុំប្រចាំខែ និងផ្សព្វផ្សាយស្តីពី ការពង្រឹងការគ្រប់គ្រងការងារបុគ្គលិក ជូនដល់ថ្នាក់ដឹកនាំ និងមន្ត្រីរាជការ របស់មន្ទីរអភិវឌ្ឍន៍ជនបទខេត្តព្រះសីហនុ
- បានទទួលប្រកាសស្តីពីការផ្ទេរភារកិច្ច មន្ត្រី០១រូប ពីប្រធានការិយាល័យគណនេយ្យ និងហិរញ្ញវត្ថុ នៃមន្ទីរអភិវឌ្ឍន៍ជនបទ រាជធានីភ្នំពេញ មកបម្រើការងារជាមន្ត្រី នៅមន្ទីរអភិវឌ្ឍន៍ជនបទ ខេត្តព្រះសីហនុ និងបានធ្វើការផ្ទេរចេញ មន្ត្រី០១រូប ពីអនុប្រធានការិយាល័យគណនេយ្យ និងហិរញ្ញ វត្ថុ នៃមន្ទីរអភិវឌ្ឍន៍ជនបទ ខេត្តព្រះសីហនុ ទៅបម្រើការងារជាមន្ត្រី នៅនាយកដ្ឋានផ្គត់ផ្គង់ និងហិរញ្ញវត្ថុ នៃក្រសួងអភិវឌ្ឍន៍ជនបទ
- បានធ្វើរបាយការណ៍ស្តីពី ការផ្លាស់ប្តូរស្ថានភាពរដ្ឋបាល និងស្ថានភាពគ្រួសាររបស់មន្ត្រីរាជការស៊ីវិល
- បានធ្វើរបាយការណ៍ស្តីពីបច្ចុប្បន្នភាព នៃការបើកផ្តល់បៀវត្សតាមប្រព័ន្ធធនាគារ របស់មន្ត្រីរាជការ
- បានធ្វើរបាយការណ៍ស្តីពីសំណើ សំណូមពរ និងបញ្ហាទាក់ទងនឹងការងារក្រសួងអភិវឌ្ឍន៍ជនបទ របស់ប្រជាពលរដ្ឋនៅមូលដ្ឋានខេត្តព្រះសីហនុ ជូនក្រុមការងារចុះមូលដ្ឋានក្រសួងអភិវឌ្ឍន៍ជនបទ
- បានផ្តល់តម្រូវការផែនការក្របខ័ណ្ឌមន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យា សម្រាប់ឆ្នាំ២០២៣
- បានផ្តល់បញ្ជីរាយនាមមន្ត្រីរាជការ ចំនួន០៣រូប ដែលត្រូវស្នើសុំគ្រឿងឥស្សរិយយស និងមេដាយការងារ សម្រាប់ឆ្នាំ២០២២
- បានផ្តល់បញ្ជីរាយនាមមន្ត្រីរាជការ ចំនួន០៣រូប ដែលត្រូវដំឡើងថ្នាក់ និងឋានន្តរស័ក្តិ សម្រាប់ឆ្នាំ២០២៣

- ថ្នាក់ដឹកនាំ និងមន្ត្រីរាជការរបស់មន្ទីរអភិវឌ្ឍន៍ជនបទ ខេត្តព្រះសីហនុ បានចូលរួមបរិច្ចាកថវិកាក្នុងយុទ្ធនាការបោសសម្អាតមីន និងកម្ពុជាគ្មានមីននៅឆ្នាំ២០២៥ តបតាមការអំពាវនាវរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានចំនួន ១,៣០០,០០០ រៀល
- ថ្នាក់ដឹកនាំ និងមន្ត្រីរាជការរបស់មន្ទីរអភិវឌ្ឍន៍ជនបទ ខេត្តព្រះសីហនុ ចំនួន ០៥រូប បានស្ម័គ្រចិត្តចូលរួមបរិច្ចាកឈាម តាមការអំពាវនាវរបស់រដ្ឋបាលខេត្តព្រះសីហនុ នៅមជ្ឈមណ្ឌលមង្គលសេដ្ឋាច័ន្ទ ក្រុងព្រះសីហនុ
- ថ្នាក់ដឹកនាំមន្ទីរបានចូលរួមប្រជុំជាមួយគណៈអភិបាលខេត្ត និងអង្គភាពផ្សេងៗបានចំនួន ១៣០ លើក។

**១.២.ការងារបណ្តុះបណ្តាលវិជ្ជាជីវៈ និងអប់រំផ្សព្វផ្សាយ ដល់មន្ត្រីរាជការ**

- ថ្នាក់ដឹកនាំ និងមន្ត្រីរាជការបានចូលរួមវគ្គបណ្តុះបណ្តាល បានចំនួន ១២លើក អ្នកចូលរួមចំនួន៣០នាក់ (ស្រី០១នាក់)
- ថ្នាក់ដឹកនាំ និងមន្ត្រីរាជការបានចូលរួមសិក្ខាសាលា បានចំនួន ១៤លើក អ្នកចូលរួមចំនួន ៤៣នាក់ (ស្រី០៣នាក់)។

**១ការ.៣.ងារផែនការ**

- បានធ្វើរបាយការណ៍បូកសរុបលទ្ធផលការងាររបស់មន្ទីរ ជាប្រចាំខែ ត្រីមាស ឆមាស ៩ ខែ និងប្រចាំឆ្នាំ២០២២ ជូនក្រសួងអភិវឌ្ឍន៍ជនបទ និងរដ្ឋបាលខេត្តព្រះសីហនុ
- បានចូលរួមសិក្ខាសាលាសមាហរណកម្ម កម្មវិធីវិនិយោគបីឆ្នាំរំកិល (២០២៤-២០២២) របស់រដ្ឋបាលក្រុងស្រុក ឃុំ សង្កាត់ នៅតាមបណ្តាក្រុង ស្រុក ក្នុងខេត្តព្រះសីហនុ
- បានធ្វើផែនការការងាររបស់មន្ទីរសម្រាប់ឆ្នាំ ២០២៣ ជូនទៅក្រសួងអភិវឌ្ឍន៍ជនបទ
- បានចូលរួមប្រជុំរៀបចំកែសម្រួល សេចក្តីព្រាងកម្មវិធីវិនិយោគបីឆ្នាំរំកិល (២០២៤-២០២២) របស់រដ្ឋបាលខេត្ត
- បានចូលរួមប្រជុំផ្សព្វផ្សាយស្តីពីការរៀបចំ និងការកសាងកម្មវិធីបីឆ្នាំរំកិល (២០២៣-២០២៥) របស់រដ្ឋបាលខេត្តព្រះសីហនុ ជំហានទី១))
- បានធ្វើផែនការការងារ៣ឆ្នាំរំកិល ២០)២៣២០២-៥ (ជូនទៅគណៈអភិបាល និងក្រុមប្រឹក្សាខេត្ត
- បានចូលរួមប្រជុំពិភាក្សា ពិនិត្យ និងកែសម្រួលសេចក្តីណែនាំ ស្តីពីការរៀបចំ និងកសាងកម្មវិធីវិនិយោគ៣ឆ្នាំរំកិល (២០២៣២០២៥-) របស់រដ្ឋបាលខេត្តព្រះសីហនុ
- បានចូលរួមសិក្ខាសាលាស្តីពី ការរៀបចំផែនការយុទ្ធសាស្ត្រថវិកា ឆ្នាំ២០២៣-២០២៥ និងថវិកាសមិទ្ធកម្ម ឆ្នាំ២០២៣ របស់ក្រសួងអភិវឌ្ឍន៍ជនបទ នៅសណ្ឋាគារឆ្នេរសុខា ខេត្តព្រះសីហនុ
- បានចូលរួមសិក្ខាសាលាស្តីពី ការរៀបចំផែនការយុទ្ធសាស្ត្រថវិកា ឆ្នាំ២០២៣-២០២៥ និងគម្រោងថវិកា ឆ្នាំ២០២៣ លើវិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ នៅខេត្តសៀមរាប

- បានចូលរួមកិច្ចប្រជុំស្តីពី ការងារអភិរក្ស និងការអភិវឌ្ឍន៍ជនជាតិដើមភាគតិច ប្រចាំឆមាសទី១ ឆ្នាំ២០២២ នៅទីស្តីការក្រសួងអភិវឌ្ឍន៍ជនបទ
- បានចូលរួមកិច្ចប្រជុំពិគ្រោះយោបល់ស្តីពី ការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០២៣-២០២៥ និងថវិកាព័ត៌មានសមិទ្ធកម្មឆ្នាំ២០២៣ លើវិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ តាមរយៈប្រព័ន្ធអនឡាញ Zoom។

**១.៤.ការងារគណនេយ្យ និងហិរញ្ញវត្ថុ**

- បានរៀបចំឯកសារបើកប្រាក់បៀវត្សប្រចាំខែ ប្រាក់ឧបត្ថម្ភក្នុងឱកាសពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិ ប្រាក់ឧបត្ថម្ភក្នុងឱកាសពិធីបុណ្យភ្ជុំបិណ្ឌ និងប្រាក់បេសកកម្មជូនមន្ត្រីរាជការទាន់ពេលវេលា
- បានរៀបចំសៀវភៅសលាប័ត្រតាមដានការប្រើប្រាស់ឥណទាន ឆ្នាំ២០២២
- បានរៀបចំឯកសារបើក និងទូទាត់រង្វាន់ទេយ្យបុរេប្រទានចំនួន ០៤ដុំ ឆ្នាំ២០២២
- បានរៀបចំបញ្ជីសារពើភ័ណ្ឌសៀវភៅគោល ឆ្នាំ២០២២
- បានរៀបចំឯកសារអនុវត្តកិច្ចលទ្ធកម្មចំនួន ០៩ គម្រោង រួមមាន ប្រេងឥន្ធនៈ និងប្រេងរំអិល, សម្ភារៈការិយាល័យ, ជួសជុលអគារ និងធ្វើរបងមន្ទីរ, ជួសជុលផ្លូវប្រវែង ២.៨៩០ ម៉ែត្រ ទទឹង៤ម៉ែត្រ, សម្ភារៈផ្គត់ផ្គង់សម្រាប់ថែទាំអគារ, ស្បៀងសម្រាប់រដ្ឋបាល, ពូជ និងកូនរុក្ខជាតិ, សម្ភារៈនិងបរិក្ខាបច្ចេកទេសមិនមែនព័ត៌មានវិទ្យា, សោហ៊ុយទទួលភ្ញៀវជាតិ ដែលក្នុងនោះការអនុវត្តនីតិវិធីស្ទង់តម្លៃ ០៥គម្រោង ពិគ្រោះថ្លៃចំនួន០៣គម្រោង និងការអនុវត្តនីតិវិធីដេញថ្លៃដោយប្រកួតប្រជែងជាសាធារណៈចំនួន០១គម្រោង
- បានរៀបចំអាណត្តិទូទាត់ការប្រើប្រាស់អគ្គីសនី និងការប្រើប្រាស់អ៊ីនធឺណេតរៀងរាល់ខែ
- បានធ្វើការទំនាក់ទំនងការងារជាមួយក្រសួងអភិវឌ្ឍន៍ជនបទ និងធនាគារជាតិ ដើម្បីបើកថវិកាការងារថែទាំផ្លូវ ការងារសាងសង់អណ្តូងស្នប់អាហ្វ្រីដេវ និងការងារផ្គត់ផ្គង់សម្ភារៈសាងសង់បង្គន់អនាម័យ បានចំនួន១៣លើក។

**១.៥.ការងារសវនកម្ម និងអធិការកិច្ច**

- បានចូលរួមកិច្ចប្រជុំបើកការធ្វើសវនកម្មសម្រាប់ការិយបរិច្ឆេទ២០២១និងឆ្នាំពាក់ព័ន្ធតាមប្រព័ន្ធ Online Zoom។
- ក្រុមការងារសវនកម្មក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានចុះធ្វើអធិការកិច្ចហិរញ្ញវត្ថុ លើការគ្រប់គ្រង ការអនុវត្តចំណូល-ចំណាយថវិការដ្ឋ ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ក្នុងការិយបរិច្ឆេទ២០២១ និងឆ្នាំពាក់ព័ន្ធ ត្រួតពិនិត្យសាឡើងវិញនូវបណ្តាវិធានការរបស់គណៈប្រតិភូអធិការកិច្ចហិរញ្ញវត្ថុ ដែលបានលើកឡើងក្នុងការត្រួតពិនិត្យការិយបរិច្ឆេទ២០២០
- ក្រុមការងារអាជ្ញាធរសវនកម្មជាតិ បានចុះធ្វើសវនកម្មលើការគ្រប់គ្រងហិរញ្ញវត្ថុ ការអនុលោមតាមបទបញ្ញត្តិការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និងកិច្ចប្រតិបត្តិការការងារ សម្រាប់ការិយបរិច្ឆេទ២០២១ និងឆ្នាំពាក់ព័ន្ធ
- ក្រុមការងារក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានចុះធ្វើការត្រួតពិនិត្យកិច្ចលទ្ធកម្មតាមក្រោយដែលបានអនុវត្តរួច និងស្ថិតក្រោមសិទ្ធិសម្រេចលើការិបរិច្ឆេទ២០២១
- ក្រុមការងារនាយកដ្ឋានសវនកម្មផ្ទៃក្នុង ក្រសួងអភិវឌ្ឍន៍ជនបទ បានចុះធ្វើសវនកម្មលើប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុង និងថវិកាកម្មវិធី ឆ្នាំ២០២១-២០២២

- ក្រុមការងារអគ្គាធិការដ្ឋានក្រសួងអភិវឌ្ឍន៍ជនបទ បានចុះធ្វើអធិការកិច្ចគ្រប់គ្រងរដ្ឋបាលហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋកាលបរិច្ឆេទ ឆ្នាំ២០២១
- ក្រុមការងារក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច បានចុះធ្វើអធិ-ការកិច្ចលើការអនុវត្តតួនាទី ភារកិច្ច ការគ្រប់គ្រងផ្តល់សេវាសធារណៈ និងការអនុវត្តកិច្ចលទ្ធកម្មសាធារណៈ ក្នុងការិយបរិច្ឆេទឆ្នាំ២០២១ និងបណ្តាឆ្នាំពាក់ព័ន្ធ។

**១.៦.ការងារយេនឌ័រ**

- ថ្នាក់ដឹកនាំ និងមន្ត្រីរាជការរបស់មន្ទីរ បានចូលរួមសិក្ខាសាលាស្តីពីការផ្សព្វផ្សាយទស្សនៈយេនឌ័រក្នុងវិស័យអភិវឌ្ឍន៍ជនបទ នៅសាលប្រជុំមន្ទីរអភិវឌ្ឍន៍ជនបទ ខេត្តព្រះសីហនុ ក្រោមអធិបតីភាព **លោកជំទាវ ម៉ាត់ ម៉ារ៉ា** រដ្ឋលេខាធិការ និងជាប្រធានក្រុមការងារ យេនឌ័រ ក្រសួងអភិវឌ្ឍន៍ជនបទ
- ថ្នាក់ដឹកនាំមន្ទីរ បានផ្តល់ជាវត្ថុអនុស្សាវរីយ៍លើកទឹកចិត្ត ជូនដល់អនុប្រធានការិយាល័យ ០១រូប ជាស្ត្រី ក្នុងឱកាសទិវាអន្តរជាតិនារី ខួបទី១១១ ឆ្នាំ២០២២ ក្រោមប្រធានបទសមភាពយេនឌ័រ ថ្ងៃនេះ ដើម្បីចីរភាពនាពេលអនាគត
- អនុប្រធានមន្ទីរ០១រូប បានចូលរួមប្រជុំជារៀងរាល់ខែជាមួយគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារខេត្ត (គ.ក.ស.ក) នៅសាលាខេត្តព្រះសីហនុ
- អនុប្រធានការិយាល័យ ០១រូប បានចូលរួមប្រជុំជារៀងរាល់ខែ ជាមួយគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារក្រុង (គ.ក.ស.ក ក្រុង)នៅសាលាក្រុងព្រះសីហនុ។

**១.៧.ការងារជនពិការ**

- បានផ្តល់ស្ថិតិមន្ត្រីរាជការមានពិការភាព ចំនួន០៤រូប ដែលកំពុងបម្រើការងារនៅមន្ទីរអភិវឌ្ឍន៍ជនបទខេត្ត ជូនក្រុមការងារសកម្មភាពជនពិការក្រសួងអភិវឌ្ឍន៍ជនបទ។

**១.៨.ការងារអេដស៍**

- បានចូលរួមជុំផ្សព្វផ្សាយស្តីពី លទ្ធផលការអង្កេតអត្រាប្រេវ៉ាឡង់មេរោគអេដស៍ ជំងឺអេដស៍ ជំងឺកាមរោគ ឆ្នាំ២០២២ និងស្ថានភាពមេរោគអេដស៍/ជំងឺអេដស៍ សម្រាប់ត្រីមាសទី៣ ឆ្នាំ២០២២ នៅមន្ទីរសុខាភិបាលខេត្តព្រះសីហនុ។

**១.៩.ការងារកែទម្រង់ហិរញ្ញវត្ថុសាធារណៈ**

- បានចូលរួមសិក្ខាសាលាស្តីពី គោលការណ៍ណែនាំ ស្តីពីការរៀបចំថវិកាព័ត៌មានសមិទ្ធកម្ម របស់ក្រសួងអភិវឌ្ឍន៍ជនបទ តាមប្រព័ន្ធអនឡាញ zoom
- បានចូលរួមកិច្ចប្រជុំផ្សព្វផ្សាយសារាចរណែនាំ លេខ០១៣ សហវ ស្តីពីការអនុវត្តច្បាប់ស្តីពីហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រង ឆ្នាំ២០២២ និងជំរុញការរៀបចំរបាយការណ៍អនុវត្តថវិកា ឆ្នាំ២០២១ ដល់អង្គភាពថវិកាមន្ទីរជំនាញ នៅសាលប្រជុំមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ខេត្តព្រះសីហនុ
- បានចូលរួមវគ្គបណ្តុះបណ្តាលគោលការណ៍ណែនាំ ស្តីពីការរៀបចំថវិកាសមិទ្ធកម្ម ឆ្នាំ២០២២ តាមប្រព័ន្ធ Online Zoom
- បានចូលរួមវគ្គបណ្តុះបណ្តាលស្តីពី នីតិវិធីគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ តាមប្រព័ន្ធ Online Zoom
- បានចូលរួមសិក្ខាសាលាស្តីពី ការរៀបចំផែនការយុទ្ធសាស្ត្រថវិកា ឆ្នាំ២០២៣-២០២៥ និងថវិកាសមិទ្ធកម្ម ឆ្នាំ២០២៣ របស់ក្រសួងអភិវឌ្ឍន៍ជនបទ នៅសណ្ឋាគារឆ្នេរសុខា ខេត្តព្រះសីហនុ

- បានចូលរួមសិក្ខាសាលាស្តីពី ការរៀបចំផែនការយុទ្ធសាស្ត្រថវិកា ឆ្នាំ២០២៣-២០២៥ និងគម្រោងថវិកាឆ្នាំ២០២៣ លើវិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ នៅខេត្តសៀមរាប។

**២.ការងារអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងគមនាគមន៍**

**២.១.ការងាររៀបចំបញ្ជីសារពើភ័ណ្ឌ និងទិន្នន័យផ្លូវជនបទ**

- បានធ្វើបច្ចុប្បន្នភាពការគ្រប់គ្រងផ្លូវជនបទ តាមប្រព័ន្ធព័ត៌មានវិទ្យា ក្នុងខេត្តព្រះសីហនុ បានចំនួន ២០២ខ្សែ ប្រវែងសរុប ៣៨១.៥០៣ម៉ែត្រ ក្នុងនោះរួមមានៈ

| | | |
|---|---|---|
| កម្រាលបេតុង | ប្រវែង ៤៥.៦៧៧ | ម៉ែត្រ |
| កម្រាលកៅស៊ូ ១ជាន់ | ប្រវែង ១២.៥០០ | ម៉ែត្រ |
| កម្រាលកៅស៊ូ ២ជាន់ | ប្រវែង ៣២.០០០ | ម៉ែត្រ |
| ក្រួសក្រហម | ប្រវែង ១០៨.៤១៤ | ម៉ែត្រ |
| ល្បាយថ្មភ្នំ | ប្រវែង ១៧០.៩៣២ | ម៉ែត្រ |
| ដីស | ប្រវែង ១២.៩៨០ | ម៉ែត្រ |
| លូ | ចំនួន ៦៨៥ | កន្លែង |
| ស្ពាន | ចំនួន ៤៣ | កន្លែង។ |

**២.២.ការងារដាំដើមឈើ**

- បានដាំកូនឈើចំនួន២០០ដើម លើខ្សែផ្លូវជនបទ ស្ថិតក្នុងឃុំសាមគ្គី ស្រុកព្រៃនប់។

**២.៣.ការងារថែទាំ ជួសជុលផ្លូវជនបទ និងសំណង់សិល្បការ្យ**

- បានថែទាំផ្លូវជាលក្ខណៈខួបចំនួន ០១ខ្សែ ប្រវែងសរុប ១១.៥០០ម៉ែត្រ ស្ថិតក្នុងឃុំសាមគ្គី ស្រុកព្រៃនប់
- បានថែទាំផ្លូវជាលក្ខណៈប្រចាំចំនួន ១៥ខ្សែ ប្រវែងសរុប ៦៦.៣០០ម៉ែត្រ ស្ថិតក្នុងឃុំអូរបាក់រទេះ ចំការហ្លួង ស្ទឹងឆាយ កំពង់សីលា នៃស្រុកកំពង់សីលា ឃុំទឹកល្អក់ អូរជ្រៅ សំរុង បឹងតាព្រហ្ម ទួលទទឹង អណ្តូងថ្ម ជើងគោ នៃស្រុកព្រៃនប់ និងឃុំទំនប់រលក ស្រុកស្ទឹងហាវ
- បានជួសជុលបន្ទាន់ផ្លូវ ០៣ខ្សែ ប្រវែង ៥.០០០ម៉ែត្រ ស្ថិតក្នុងឃុំអូរបាក់រទេះ ស្រុកំពង់សីលា និងឃុំអណ្តូងថ្ម ស្រុកព្រៃនប់
- បានជួសជុលផ្លូវដោយអនុវត្តកិច្ចលទ្ធកម្មចំនួន០១ខ្សែ ប្រវែង ២.៨៩០ម៉ែត្រ ស្ថិតនៅឃុំស្ទឹងឆាយ ស្រុកកំពង់សីលា។

**៣.ការងារកែលម្អលក្ខខណ្ឌនៃការរស់នៅរបស់សហគមន៍ជនបទ**

**៣.១.ការងារសាងសង់អណ្តូងទឹកធន់នឹងការប្រែប្រួលអាកាសធាតុ**

- បានសាងសង់អណ្តូងស្នប់ Afridev ចំនួន ១៦អណ្តូង ដែលមានទីតាំងស្ថិតក្នុងស្រុក ស្រុកកំពង់សីលា។

**៣.២.ការងារសោងសង់បង្គន់អនាម័យជនបទ**

- បានផ្តល់សម្ភារៈសម្រាប់សាងសង់បង្គន់អនាម័យ ដល់ប្រជាពលរដ្ឋក្រីក្រ ចំនួន៥០ បង្គន់ ស្ថិតនៅក្នុងឃុំអូរជ្រៅ ស្រុកព្រៃនប់។

**៣.៣.ការងារលើកកម្ពស់ការផ្លាស់ប្តូរទម្លាប់ ឲ្យមានការរស់នៅស្អាត និងមានអនាម័យនៅជនបទ**

- បានរៀបចំពិធីមិទ្ទិញអបអរសាទរ ទិវាជាតិលើកកម្ពស់អនាម័យជនបទ លើកទី១៣ នៅថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០២២ នៅក្នុងទីធ្លាសាលាបឋម-អនុវិទ្យាល័យ ឃុំអណ្ដូងថ្ម ស្រុកព្រៃនប់ ដែលមានអ្នកចូលរួមចំនួន៤០១នាក់ (ស្រី២០១នាក់)
- បានចុះណែនាំ និងជំរុញដល់គ្រួសារដែលទទួលបានសម្ភារៈ សម្រាប់សាងសង់បង្គន់អនាម័យក្នុងផែនការឆ្នាំ២០២២ អោយសាងសង់បានគ្រប់គ្រួសារ និងប្រកបដោយបច្ចេកទេស
- បានចុះបើកវគ្គផ្សព្វផ្សាយគោលការណ៍ណែនាំកម្មវិធីសហគមន៍ដឹកនាំអនុវត្តអនាម័យនិងការលើកកម្ពស់អនាម័យជនបទ ចំនួន០៤វគ្គ ដែលធ្វើឡើងនៅឃុំទឹកថ្លា ឃុំជើងគោ ឃុំទួលទទឹង និងឃុំអណ្ដូងថ្ម ស្រុកព្រៃនប់ មានអ្នកចូលរួមសរុប ១៩៥នាក់ (ស្រី១៨៨នាក់)
- បានរៀបចំកិច្ចប្រជុំក្រុមការងារបច្ចេកទេស ស្ដីពីវិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ ដោយមានសមាសភាពក្រុមការងារ និងលេខាធិការដ្ឋានចូលរួមចំនួន១៩នាក់ (ស្រី០៤នាក់) អវត្តមាន០១នាក់ (ក្រុងកោះរ៉ុង) ក្រោមអធិបតីភាព **លោក ឡុង ឌីម៉ង់** អភិបាលរងខេត្តព្រះសីហនុ និងជាប្រធាន PWG ខេត្ត នៅសាលប្រជុំអគាររដ្ឋបាលខេត្តបណ្ដោះអាសន្ន
- បានចូលរួមវេទិកាចែករំលែកចំណេះដឹង និងបទពិសោធន៍ក្រោមប្រធានបទ អនាម័យក្នុងតំបន់ប្រឈម រៀបចំដោយអង្គការ waterAid នៅសណ្ឋាគារកាំបូឌីយ៉ាណា រាជធានីភ្នំពេញ
- បានចូលរួមកិច្ចប្រជុំថ្នាក់ក្រោមជាតិ ដើម្បីពន្លឿនការបញ្ឈប់ការបន្ទោបង់ ពាសវាលពាសកាល នៅកម្ពុជា ក្រោមអធិបតីភាព **ឯកឧត្តមបណ្ឌិត ជ្រុន ថេរ៉ាវ៉ាត** រដ្ឋលេខាធិការ និងជាតំណាងដ៏ខ្ពង់ខ្ពស់ **ឯកឧត្តមបណ្ឌិតសភាចារ្យ អ៊ុក រ៉ាប៊ុន** រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ នៅសណ្ឋាគារឆ្នេរសុខា ក្រុងព្រះសីហនុ
- បានសហការជាមួយក្រុមការងារនាយកដ្ឋានថែទាំសុខភាពជនបទចុះបើកកម្មវិធីប្រជុំផ្សព្វផ្សាយគោលការណ៍ណែនាំជាតិស្ដីពី សហគមន៍ដឹកនាំអនុវត្តអនាម័យ ដល់ក្រុមប្រឹក្សាឃុំ មេភូមិ អនុភូមិ សមាជិកភូមិទាំង៥ នៃឃុំអូរជ្រៅ ដែលធ្វើឡើងនៅសាលាឃុំអូរជ្រៅ ស្រុកព្រៃនប់
- បានចូលរួមសិក្ខាសាលាស្ដីពី ការរៀបចំផែនការយុទ្ធសាស្ត្រថវិកា ឆ្នាំ២០២៣-២០២៥ និងគម្រោងថវិកាឆ្នាំ២០២៣ លើវិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ នៅខេត្តសៀមរាប
- បានប្រជុំពិភាក្សាការងារជាមួយអង្គការ Plan International អំពីវិធីសាស្ត្រ ជម្រុញឲ្យស្ថានភាពអនាម័យ នៅក្នុងខេត្តព្រះសីហនុ ឈានទៅដល់ការឈប់បន្ទោបង់ពាសវាលពាសកាល ដើម្បីចុះផ្ទៀងផ្ទាត់ កំណត់ជាឃុំ ស្រុក ខេត្តទទួលបាន ODF
- បានប្រជុំពិភាក្សា និងសម្របសម្រួលជាមួយអាជ្ញាធរឃុំ និងអង្គការ CBN Cambodia លើសកម្មភាពការងារទឹកស្អាត និងអនាម័យ នៅក្នុងឃុំកំពង់សីលា ស្រុកកំពង់សីលា
- បានធ្វើសំណើអញ្ជើញមន្ត្រីជំនាញរបស់នាយកដ្ឋានថែទាំសុខភាពជនបទនិងអង្គការផ្លែន ដើម្បីចូលរួមរៀបចំនីតិវិធី និងផ្ទៀងផ្ទាត់ ឃុំ-សង្កាត់មួយចំនួនក្នុងខេត្តព្រះសីហនុ ជាឃុំ-សង្កាត់ បញ្ឈប់ការបន្ទោរបង់ពាសវាលពាសកាល (ODF)
- បានទទួលជួបពិគ្រោះយោបល់ ជាមួយក្រុមការងារក្រសួងសុខាភិបាល លើការងារប្រមូលទិន្នន័យស្ដីពីការស្ទង់មតិ ការវិភាគ និងវាយតម្លៃជាសកលលើអនាម័យ និងទឹកបរិភោគ (GLAAS Survey) នៅមន្ទីរអភិវឌ្ឍន៍ជនបទខេត្ត
- បានចូលរួមពិធីសម្ពោធដាក់អោយប្រើប្រាស់ ជាផ្លូវការបង្គន់អនាម័យចំនួន១២១បង្គន់ អណ្ដូងស្នប់ ១៥អណ្ដូង និងធុងចម្រោះ ២២៥ធុង ក្រោមជំនួយឧបត្ថម្ភគាំទ្រដោយគម្រោង អណ្ដូងទឹកស្អាត និងអនាម័យ របស់អង្គការស៊ីប៊ីអិន កម្ពុជា នៅភូមិទាំង០៤ នៃឃុំកំពង់

សីលា ស្រុកកំពង់សីលា ក្រោមអធិបតីភាព **លោក ឡុង ឌីម៉ង់** អភិបាលរង នៃគណៈអភិបាលខេត្តព្រះសីហនុ និងជាប្រធានPWGខេត្ត

- បានចូលរួមកិច្ចប្រជុំក្រុមការងារពិសេស លុបបំបាត់ជំងឺគ្រុនចាញ់ថ្នាក់ខេត្ត សម្រាប់ត្រីមាសទី៣ ដែលផ្តោតសំខាន់លើសមិទ្ធផលសកម្មភាព បញ្ហាប្រឈម និងដំណោះស្រាយរបស់កម្មវិធីគ្រុនចាញ់ ខេត្តព្រះសីហនុ ក្នុងគោលបំណងរួមគ្នាលុបបំបាត់ឲ្យអស់នូវជំងឺគ្រុនចាញ់ ស្របតាមយុទ្ធសាស្រ្តរបស់រាជរដ្ឋាភិបាលឆ្នាំ២០២៥ ជំងឺគ្រុនចាញ់ត្រូវបានលុបបំបាត់បានទាំងស្រុង ក្រោមអធិបតីភាព **លោក ឡុង ឌីម៉ង់** អភិបាលរងខេត្តព្រះសីហនុ នៅសាលប្រជុំមន្ទីរសុខាភិបាលខេត្តព្រះសីហនុ។

**៣.៤.ការងារអប់រំជំងឺឆ្លង និងសុខភាពផ្លូវភេទ**

- បានចុះផ្សព្វផ្សាយអំពីវិធីកាត់បន្ថយហានិភ័យពីការឆ្លង ជំងឺកូវីដ-១៩ និងការលើកកម្ពស់សុខភាពអនាម័យ នៅក្នុងភូមិទាំង២១ ក្នុងឃុំទឹកថ្លា ឃុំជើងគោ ឃុំអណ្តូងថ្ម និងឃុំទួលទទឹង ស្រុកព្រៃនប់។

**៤.ពិពិធកម្មសកម្មភាពសេដ្ឋកិច្ចជនបទ**

**៤.១.ការងារលើកកម្ពស់កំណើនសេដ្ឋកិច្ចគ្រួសារនៅជនបទ**

- អង្គភាពអនុវត្តន៍គម្រោងឥណទាន នៃមន្ទីរអភិវឌ្ឍន៍ជនបទខេត្តព្រះសីហនុ មានថវិកាចំនួន ២៣,១៥៦,៣០០ រៀល សម្រាប់ផ្តល់ឥណទានជនបទ ជូនប្រជាពលរដ្ឋចំនួន ០១ ក្រុម ជាស្ត្រី ដែលមានសមាជិក៥នាក់ នៅឃុំអូរជ្រៅ ស្រុកព្រៃនប់
- បានចូលរួមកិច្ចប្រជុំបូកសរុបលទ្ធផលការងារគម្រោងឥណទាន ក្រសួងអភិវឌ្ឍន៍ជនបទប្រចាំឆ្នាំ២០២១ និងទិសដៅការងារឆ្នាំ២០២២ នៅមន្ទីរអភិវឌ្ឍន៍ជនបទ ខេត្តស្ទឹងត្រែង
- បានចូលរួមកិច្ចប្រជុំបូកសរុបលទ្ធផលការងារឥណទាន ប្រចាំឆមាសទី១ និងទិសដៅការងារបន្ត ឆ្នាំ២០២២ នៅទីស្តីការក្រសួងអភិវឌ្ឍន៍ជនបទ រាជធានីភ្នំពេញ
- បានចូលរួមវគ្គបណ្តុះបណ្តាលស្តីពី ការគ្រប់គ្រងឥណទានជនបទ នៅខេត្តសៀមរាប។

**៤.២.ការងារអភិវឌ្ឍន៍សហគមន៍**

- បានចុះធ្វើបច្ចុប្បន្នភាពគណៈកម្មាធិការអភិវឌ្ឍន៍ភូមិ (គ.អ.ភ) បានចំនួន២៧ភូមិ ក្នុងឃុំទាំង០៨ នៃស្រុកស្ទឹងហាវ និងស្រុកកំពង់សីលា មានសមាជិកសរុប២២១ នាក់ ស្រី៥៤ នាក់ បានធ្វើការផ្លាស់ប្តូរសមាជិកសរុប ១០០នាក់ ស្រី២៩នាក់។

**៤.៣.ការងារអភិវឌ្ឍន៍ និងអភិរក្សជនជាតិដើមភាគតិច**

- បច្ចុប្បន្នខេត្តព្រះសីហនុ មានក្រុមជនជាតិដើមភាគតិចស្អូច កំពុងរស់នៅភូមិសំរុងលើ ឃុំសំរុង ស្រុកព្រៃនប់ ដែលត្រូវបានក្រសួងអភិវឌ្ឍន៍ជនបទ យល់ព្រមទទួលស្គាល់អត្តសញ្ញាណតាមលិខិតលេខ ០៤៥២/២២ ក.អ.ជ ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២២ មានចំនួន៤១ គ្រួសារ សមាជិកសរុប១៣៤នាក់ (ស្រី៧០នាក់)
- បានចូលរួមកិច្ចប្រជុំស្តីពី ការងារអភិរក្ស និងការអភិវឌ្ឍន៍ជនជាតិដើមភាគតិច ប្រចាំឆមាសទី១ ឆ្នាំ២០២២ នៅទីស្តីការក្រសួងអភិវឌ្ឍន៍ជនបទ
- បានចូលរួមទិវាអន្តរជាតិជនជាតិដើមភាគតិចពិភពលោកលើកទី២៨ និងលើកទី១៨ នៅកម្ពុជា ក្រោមអធិបតីភាព **ឯកឧត្តមបណ្ឌិត សួស គង់** រដ្ឋលេខាធិការប្រចាំការ តំណាងដ៏ខ្ពង់ខ្ពស់ **ឯកឧត្តមបណ្ឌិតសភាចារ្យ អ៊ុក រ៉ាប៊ុន** រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ នៅសាលមហោស្រប ខេត្តក្រចេះ
- បានចូលរួមកិច្ចប្រជុំស្តីពី ផែនការសកម្មភាពការងារអភិវឌ្ឍន៍ជនជាតិដើមភាគតិច ក្រោម

អធិបតីភាព **ឯកឧត្តម សួន សេរីរដ្ឋា** រដ្ឋលេខាធិការ នៅទីស្តីការក្រសួងអភិវឌ្ឍន៍ជនបទ

- បានចូលរួមសិក្ខាសាលាតម្រង់ទិសស្តីពី នីតិវិធីនៃការវាយតម្លៃកំណត់អត្តសញ្ញាណក្រុមជនជាតិដើមភាគតិច និងបូកសរុបលទ្ធផលការងារជាមួយអង្គការដៃគូអភិវឌ្ឍន៍ ក្រោមអធិបតីភាព **ឯកឧត្តម សួន សេរីរដ្ឋា** រដ្ឋលេខាធិការ នៅទីស្តីការក្រសួងអភិវឌ្ឍន៍ជនបទ។

## II. បញ្ហាប្រឈម

- ការអភិវឌ្ឍក្នុងមូលដ្ឋានមានច្រើន តែថវិកាគាំទ្រមិនទាន់ឆ្លើយតបនិងតម្រូវការ
- បរិមាណមន្ត្រីរាជការមានកម្រិតតិច មិនទាន់ឆ្លើយតបបានទៅនឹងទំហំការងារជាក់ស្តែង ដូចជាការិយាល័យខ្លះមានតែមន្ត្រីបង្គោលតែម្នាក់គត់
- សមត្ថភាពការងារជំនាញបច្ចេកទេស របស់មន្ត្រីរាជការនៅមានកម្រិត រីឯសមត្ថភាពក្នុងការសម្របសម្រួលជាមួយសហគមន៍ និងអាជ្ញាធរមូលដ្ឋាន មានពេលខ្លះពុំទាន់បានល្អប្រសើរ
- ខ្វះមធ្យោបាយធ្វើដំណើរ ដឹកសម្ភារៈ (រថយន្ត) សម្រាប់ចុះបំពេញការងារ
- ពុំមានការគាំទ្រពីអង្គការជាតិ និងអន្តរជាតិឡើយ ហេតុនេះកម្មវិធីអភិវឌ្ឍន៍នានា ពិសេសផ្នែកហេដ្ឋារចនាសម្ព័ន្ធជនបទនៅមូលដ្ឋានពឹងផ្អែកទាំងស្រុងលើថវិការបស់រាជរដ្ឋាភិបាល និងក្រសួងអភិវឌ្ឍន៍ជនបទ
- បរិមាណមធ្យោបាយដឹកជញ្ជូនលើផ្លូវជនបទកាន់តែមានកំណើន និងជាតំបន់ជាប់មាត់ សមុទ្រសម្បូរដោយភ្លៀងជោគជាំ និងជំនន់ទឹកភ្លៀងញឹកញាប់ ធ្វើឲ្យផ្លូវជនបទ ដែលក្រាលក្រួសក្រហមមួយចំនួនងាយរងនូវភាពទន់ជ្រាយខូចខាតជាអន្លើ
- តម្រូវឲ្យមានការអប់រំជាប្រចាំ ដើម្បីផ្លាស់ប្តូរនូវផ្នត់គំនិតប្រតិបត្តិអនាម័យល្អ និងយូរអង្វែង ប៉ុន្តែលទ្ធភាពនៃថវិកាសម្រាប់បម្រើឲ្យកិច្ចការនេះ នៅមានតិចតួចនៅឡើយ
- ខេត្តព្រះសីហនុមានស្ថានភាពដី ភ្នំ ខ្ពង់រាប និងជាប់មាត់សមុទ្រគឺសម្បូរដោយ តំបន់ បរិស្ថានប្រឈម
- បរិមាណនៃការផ្គត់ផ្គង់ទឹកដោយប្រព័ន្ធទុយយោរបស់រដ្ឋ ឬក្រុមហ៊ុនឯកជន មានតែនៅទីក្រុង និងទីប្រជុំជនប៉ុណ្ណោះ
- ប្រជាពលរដ្ឋនៅតំបន់ជនបទមួយចំនួនពុំមានប្រភពទឹកប្រើប្រាស់ ពិសេសនៅរដូវប្រាំងជួបការលំបាក
- បរិមាណអណ្តូងស្នប់ អណ្តូងលូ ស្រះទឹក មានចំនួនតិចតួចពុំទាន់មានតុល្យភាពជាមួយសំណូមពរ និងតម្រូវការនៅឡើយ។

## III. ទិសដៅការងារឆ្នាំ ២០២៣

### ១.ការពង្រឹងស្ថាប័ន និងកសាងសមត្ថភាព

### ១.១.ការងាររដ្ឋបាល និងបុគ្គលិក

- គ្រប់គ្រងលិខិតចេញ-ចូលរបស់មន្ទីរ
- ពង្រឹងការងាររដ្ឋបាល និងការគ្រប់គ្រងបញ្ជីវត្តមានមន្ត្រីរាជការ
- បន្តរៀបចំកិច្ចប្រជុំប្រចាំខែឲ្យបានទៀតទាត់
- ស្នើសុំមន្ត្រីក្របខណ្ឌសម្រាប់ឆ្នាំ២០២៣
- ស្នើសុំដំឡើងឋានន្តរសក្តិ និងថ្នាក់ ជូនមន្ត្រីរាជការសម្រាប់ឆ្នាំ២០២៣
- ស្នើសុំគ្រឿងឥស្សរិយយស និងមេដាយការងារ ជូនមន្ត្រីរាជការសម្រាប់ឆ្នាំ២០២៣។

**១.២.ការងារបណ្តុះបណ្តាលវិជ្ជាជីវៈ និងអប់រំផ្សព្វផ្សាយ ដល់មន្ត្រីរាជការ**

- សិក្សាវាយតម្លៃតម្រូវការបណ្តុះបណ្តាលដល់មន្ត្រីរាជការក្នុងអង្គភាព
- រៀចចំផែនការបណ្តុះបណ្តាលពង្រឹងសមត្ថភាពមន្ត្រីរាជការ ការងារបច្ចេកទេសរដ្ឋបាល) (...ហិរញ្ញវត្ថុ ភាសាបរទេស។

**១.៣.ការងារផែនការ**

- បន្តធ្វើរបាយការណ៍បូកសរុបលទ្ធផលការងាររបស់មន្ទីរ ជាប្រចាំខែ ត្រីមាស ឆមាស ៩ ខែ និងប្រចាំឆ្នាំ២០២៣
- បន្តធ្វើផែនការការងារ០៣ឆ្នាំរំកិល ជូនទៅគណៈអភិបាល និងក្រុមប្រឹក្សាខេត្ត
- បន្តធ្វើផែនការការងាររបស់មន្ទីរសម្រាប់ឆ្នាំ ២០២៣ ជូនទៅក្រសួងអភិវឌ្ឍន៍ជនបទ។

**១.៤.ការងារផ្គត់ផ្គង់ និងហិរញ្ញវត្ថុ**

- បន្តរៀបចំឯកសារបើប្រាក់បៀវត្ស និងប្រាក់បេសកកម្មជូនមន្ត្រីរាជការ
- សម្របសម្រួលជំពូកថវិកា និងរាល់ការចំណាយរបស់មន្ទីរ
- ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋរបស់អង្គភាព
- រៀបចំផែនការលទ្ធកម្មប្រចាំឆ្នាំ
- អនុវត្តផែនការលទ្ធកម្ម។

**១.៥.ការងារយេនឌ័រ**

- ចូលរួមរៀបចំពិធីអបអរសាទរទិវាអន្តរជាតិនារី ០៨មីនា ឆ្នាំ២០២៣ ខួបលើកទី១១២
- ចូលរួមក្នុងកិច្ចប្រជុំរបស់គណៈកម្មាធិការពិគ្រោះយោបល់ស្ត្រី និងកុមារ គ).ក.ស.ក ( ក្រុង-ខេត្ត។

**២.ការងារអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងគមនាគមន៍**

**២.១.ការងាររៀបចំបញ្ជីសារពើភ័ណ្ឌ និងទិន្នន័យផ្លូវជនបទ**

- ប្រមូលទិន្នន័យពីគ្រប់ប្រភពសម្រាប់ធ្វើបញ្ជីសារពើភ័ណ្ឌផ្លូវជនបទក្នុងខេត្ត
- គ្រប់គ្រង និងធ្វើបច្ចុប្បន្នភាពទិន្នន័យផ្លូវជនបទ។

**២.២.ការងារថែទាំផ្លូវជនបទ និងសំណង់សិល្បការ្យ**

- បន្តជួសជុល ថែទាំផ្លូវ និងសំណង់សិល្បការ្យដែលរងការខូចខាតក្នុងឆ្នាំ២០២២ និងធ្វើការជួសជុលថែទាំផ្លូវក្រួសក្រហម ដោយប្រើប្រាស់ផែនការថវិកាកម្មវិធីប្រចាំឆ្នាំ២០២៣។

**៣.ការងារកែលម្អលក្ខខណ្ឌនៃការរស់នៅរបស់សហគមន៍ជនបទ**

**៣.១.ការងារសាងសង់អណ្តូងទឹកធន់នឹងការប្រែប្រួលអាកាសធាតុ**

- បន្តសាងសង់អណ្តូងស្នប់ថ្មី តាមផែនការឆ្នាំ២០២៣។

**៣.៤.ការងារសាងសង់បង្គន់អនាម័យជនបទ**

- ផ្តល់សម្ភារៈសាងសង់បង្គន់អនាម័យ ជូនដល់គ្រួសារដែលគ្មានលទ្ធភាព សាងសង់បង្គន់អនាម័យដោយខ្លួនឯងផ្ទាល់ នៅតាមភូមិ ឃុំគោលដៅ តាមផែនការឆ្នាំ២០២៣។

**៣.៥.ការងារលើកកម្ពស់ការផ្លាស់ប្តូរទម្លាប់ ឲ្យមានការរស់នៅស្អាត និងមានអនាម័យនៅជនបទ**

- បន្តបើកវគ្គផ្សព្វផ្សាយ គោលការណ៍ណែនាំកម្មវិធីសហគមន៍ដឹកនាំអនុវត្តអនាម័យ និងការលើកកម្ពស់អនាម័យជនបទ នៅតាមឃុំគោលដៅ តាមផែនការឆ្នាំ២០២៣។

**៤.ពិពិធកម្មសកម្មភាពសេដ្ឋកិច្ចជនបទ**

**៤.១.ការងារលើកកម្ពស់កំណើនសេដ្ឋកិច្ចគ្រួសារនៅជនបទ**

- ផ្សព្វផ្សាយ និងផ្ដល់ប្រាក់កម្ចីឥណទានជនបទ ជូនប្រជាពលរដ្ឋក្នុងភូមិ ឃុំគោលដៅ
- បន្តចុះពង្រឹងសមត្ថភាពគណៈកម្មាធិការអភិវឌ្ឍន៍ភូមិ (គ.អ.ភ)។

**៤.២.ការងារអភិវឌ្ឍន៍ និងអភិរក្សជនជាតិដើមភាគតិច**

- ធ្វើបច្ចុប្បន្នភាពទិន្នន័យជនជាតិភាគតិច ដើម្បីកំណត់ឲ្យបានច្បាស់អំពី អត្តសញ្ញាណ ប្រពៃណី វប្បធម៌ ទំនៀមទំលាប់។

## សេចក្ដីសន្និដ្ឋាន

លទ្ធផលដែលសម្រេចបានក្នុងរយៈពេល០១ឆ្នាំកន្លងមកនេះ គឺពិតជាមកពីការខិតខំយកចិត្តទុកដាក់ក្នុងការបំពេញភារកិច្ច ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ របស់មន្ត្រីរាជការ បុគ្គលិកនៃមន្ទីរអភិវឌ្ឍន៍ជនបទខេត្តព្រះសីហនុ ពិសេសការដឹកនាំ ណែនាំដោយផ្ទាល់ប្រកបដោយភាពម៉ឺងម៉ាត់ ឆ្លាតវៀងវៃ រហ័សរហួន មានតម្លាភាព និងមានប្រសិទ្ធិភាពរបស់ **ឯកឧត្ដមបណ្ឌិតសភាចារ្យ អ៊ុក រ៉ាប៊ុន** រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ ដែលជាប្រមុខដឹកនាំរបស់ក្រសួង ក៏ដូចជាថ្នាក់ដឹកនាំគ្រប់លំដាប់ថ្នាក់ របស់ក្រសួង និងនាយកដ្ឋានជំនាញនានារបស់ក្រសួង ដែលបានជួយបង្កគ្រប់ លក្ខណៈសម្បត្តិ ងាយស្រួលទាំងស្មារតី សម្ភារៈ និងថវិកា ដែលជាប្រភពទុនដ៏សំខាន់អាចឲ្យមន្ទីរអភិវឌ្ឍន៍ជនបទខេត្តព្រះសីហនុ ធ្វើការងារអភិវឌ្ឍន៍នៅមូលដ្ឋានបានលទ្ធផលល្អ និងមានការរីកចម្រើនជារៀងរាល់ឆ្នាំ។

ព្រមជាមួយនោះ លទ្ធផលទាំងនេះ ពិតជាមិនអាចខ្វះបានពីការដឹកនាំ ចង្អុលណែនាំដោយផ្ទាល់ ពីក្រុមប្រឹក្សាខេត្ត គណៈអភិបាលខេត្ត និងការរួមសហការណ៍ពីស្ថាប័នពាក់ព័ន្ធក្នុងខេត្ត អាជ្ញាធរគ្រប់លំដាប់ថ្នាក់ សប្បុរសជន វិនិយោគគិន និងប្រជាពលរដ្ឋទូទាំងខេត្ត ព្រមជាមួយនឹងការខិតខំយកចិត្តទុកដាក់បំពេញភារកិច្ច ប្រកបដោយស្មារតីអំណត់ព្យាយាម មុះមុតរបស់មន្ត្រីរាជការម្នាក់ៗក្នុង មន្ទីរ ក្រោមឆ្លងសាមគ្គីភាពរឹងមាំ និងក្រោមមាគ៌ាដឹកនាំដ៏ត្រឹមត្រូវរបស់ រាជរដ្ឋាភិបាលនៃព្រះរាជាណា ចក្រកម្ពុជា ដែលមាន **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី បានធ្វើឲ្យ មន្ទីរអភិវឌ្ឍន៍ជនបទខេត្ត ត្រូវបានទទួលការវាយតម្លៃខ្ពស់ និងការគាំទ្រ ពីអាជ្ញាធរខេត្ត ក្រុង ស្រុក ស្ថាប័នពាក់ព័ន្ធ និងបានរួមចំណែកយ៉ាងសកម្មក្នុងការជម្រុញ លើកកម្ពស់ជីវភាពរស់នៅរបស់ប្រជា ពលរដ្ឋក្នុងមូលដ្ឋាន និងរួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ **ស្របតាមគោលដៅជា យុទ្ធសាស្ត្រដែលរាជរដ្ឋាភិបាល និងក្រសួងអភិវឌ្ឍន៍ជនបទ** បានដាក់ចុះ។

**ប្រធានមន្ទីរ**